ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ០១ ប្រកព

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃសុក្រ ៧រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
# ត្រូវនឹងថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃសុក្រ ៧រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង៨និង១៨នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើៈ

១- សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។
២- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត។
៣- សេចក្តីព្រាងគោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ឆ្នាំ២០២២-២០៣៨។
៤- សេចក្តីព្រាងគោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧។
៥- បញ្ហាផ្សេងៗ។

ក្រោយពីបានស្តាប់របាយការណ៍ សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានធ្វើការពិភាក្សាផ្លាស់ប្តូរយោបល់ និងសម្រេចតាមរបៀបវារៈ ដែលមានលទ្ធផលនិងខ្លឹមសារសង្ខេបដូចខាងក្រោមៈ

## ១- សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដំបូងរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ១៩៩៣ ដើម្បីរៀបចំឱ្យមានជាក្របខ័ណ្ឌគតិយុត្តសម្រាប់របបគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ ដោយផ្តោតសំខាន់លើប្រព័ន្ធថវិកាផ្អែកលើធាតុចូល។ នៅក្នុងឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ «កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ» ដោយមានគោលដៅផ្លាស់ប្តូរប្រព័ន្ធថវិកាផ្អែកលើធាតុចូលនិងមធ្យោបាយ ឆ្ពោះទៅប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មនិងវិមជ្ឈការ ពោលគឺសំដៅប្រែក្លាយជាជំហានៗនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យទៅជាប្រព័ន្ធមួយស្របតាមបទដ្ឋាននិងឧត្តមានុវត្តន៍អន្តរជាតិ។ ជាលទ្ធផល ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ឆ្នាំ២០០៨) ត្រូវបានអនុម័តដើម្បីបើកច្រកដល់ការកែទម្រង់ប្រព័ន្ធថវិកា

តាមរយៈការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងចាប់ផ្តើមអនុវត្តសាកល្បងថវិកាកម្មវិធី។ ទោះជាយ៉ាងនេះក្តី ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ឆ្នាំ២០០៨) មិនមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការកសាងប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មនៅឡើយទេ ដែលប្រការនេះតម្រូវឱ្យមានការរៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មីឡើងវិញ ឱ្យស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងការរក្សាតុល្យភាពនៃការអនុវត្តល្អរបស់កម្ពុជា ជាមួយនឹងទិសដៅនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងកម្មវិធីកែទម្រង់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល។

សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីកសាងក្របខ័ណ្ឌគតិយុត្តគោលនិងចាំបាច់សម្រាប់ការអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ឬហៅកាត់ថា «ថវិកាសមិទ្ធកម្ម» ដែលជាម៉ូដែលសមស្របសម្រាប់កម្ពុជា ស្របតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥ ដែលជាស្នូលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ សេចក្តីព្រាងច្បាប់នេះ ក៏នឹងក្លាយជាក្របខ័ណ្ឌគតិយុត្តមួយកំណត់អំពីគោលការណ៍ជាមូលដ្ឋានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរៀបចំច្បាប់ហិរញ្ញវត្ថុ ព្រមទាំងកំណត់អំពីមុខងារនិងការទទួលខុសត្រូវរបស់តួអង្គពាក់ព័ន្ធ ក៏ដូចជាការផ្ទេរសិទ្ធិអំណាចផ្ទៃក្នុង និងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នចំពោះរាជរដ្ឋាភិបាលនិងរដ្ឋសភា ក្នុងក្របខ័ណ្ឌនៃកញ្ចប់ថវិការបស់ខ្លួន។ លើសពីនេះ ភាពជឿទុកចិត្តថវិកា គណនេយ្យភាពហិរញ្ញវត្ថុ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពសមិទ្ធកម្ម ដែលជាសសរស្តម្ភទាំងបួននៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ត្រូវបានគិតគូរបញ្ចូលគ្រប់ជ្រុងជ្រោយ សំដៅធានាប្រសិទ្ធភាពនិងចីរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កំណើនសេដ្ឋកិច្ច និងសមធម៌សង្គម។

ទស្សនាទានថ្មីនិងគោលការណ៍គន្លឹះៗដែលជាទិសដៅនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានបញ្ចូលនិងឆ្លុះបញ្ចាំងជាខ្លឹមសារនៃសេចក្តីព្រាងច្បាប់នេះ រួមមាន៖ (១) បានគិតគូរបញ្ចូលគោលការណ៍ជាមូលដ្ឋានស្តីពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (២) បានគិតគូរបញ្ចូលគោលការណ៍ជាមូលដ្ឋានស្តីពីគុណវុឌ្ឍិសម្រាប់មន្ត្រីជំនាញទទួលបន្ទុកការងារពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (៣) បានបង្កើតឱ្យមានមូលនិធិបម្រុងហិរញ្ញវត្ថុ ដែលជាប្រាក់សន្សំរបស់រដ្ឋ, (៤) ពង្រឹងការទទួលខុសត្រូវនិងគណនេយ្យភាពរបស់ក្រសួង ស្ថាប័ននិងអង្គភាពសាធារណៈប្រហាក់ប្រហែល, (៥) ផ្ទេរសិទ្ធិអំណាចឱ្យក្រសួង ស្ថាប័ន ជាពិសេសអង្គភាពថវិកា ដោយកំណត់កាន់តែច្បាស់នូវមុខងាររបស់អាណាប័កដើមខ្សែ អាណាប័កផ្ទេរសិទ្ធិ និងអាណាប័កជំនួស, (៦) បានកែសម្រួលនូវគោលការណ៍ស្តីពីការត្រួតពិនិត្យការអនុវត្តថវិការដ្ឋ, (៧) បានកំណត់នូវមុខងារជាក់លាក់សម្រាប់តួអង្គអនុវត្តថវិកាសមិទ្ធកម្ម ដែលរួមមានប្រធានកម្មវិធី ប្រធានអង្គភាពថវិកា និងប្រធានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ, (៨) បានកំណត់គោលការណ៍ជាមូលដ្ឋានស្តីពីការតាមដាននិងការវាយតម្លៃក្នុងក្របខ័ណ្ឌថវិកាសមិទ្ធកម្ម, (៩) បានកំណត់មុខងារនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនិងសវនកម្មផ្ទៃក្នុង និងមុខងារអធិការកិច្ចហិរញ្ញវត្ថុ, (១០) បានកំណត់ក្របខ័ណ្ឌពេលនៃការដាក់សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ជូនទៅគណៈរដ្ឋមន្ត្រីនិងរដ្ឋសភា ដំណាលគ្នានឹងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ, (១១) បានកំណត់នូវការផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា ជាសាធារណៈក្នុងរយៈពេល ១សប្តាហ៍បន្ទាប់ពីបញ្ជូនទៅរដ្ឋសភា និងផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល២សប្តាហ៍បន្ទាប់ពីច្បាប់នេះចូលជាធរមាន, និង (១២) ចំពោះថវិការដ្ឋបាលថ្នាក់ក្រោមជាតិ គឺក្នុងនោះ៖ ទី១ បានកំណត់

មុខងារអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ក្រុង-ស្រុក និងមេឃុំ ជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន ទី២ មុខងារជាអាណាប័ករបស់អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀតដូចជាអភិបាលនៃគណៈអភិបាលខណ្ឌ ចៅសង្កាត់ចំណុះរាជធានី និងចៅសង្កាត់ចំណុះក្រុង ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិជាធរមាន និង ទី៣ កំណត់លទ្ធភាពបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល និងថវិកាឧបសម្ព័ន្ធនៅថ្នាក់ក្រោមជាតិ ដើម្បីកែលម្អការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរ។

សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំជា ៩ជំពូក និង១០៩មាត្រា ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

## ២- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត

ការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យទឹកស្អាត គឺជាមូលដ្ឋានដ៏សំខាន់ដែលអាចទ្រទ្រង់និងត្រូវឆ្លើយតបទៅនឹងសន្ទុះអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមរបស់ព្រះរាជាណាចក្រកម្ពុជា ដែលមានការរីកចម្រើនជាលំដាប់ឥតឈប់ឈរពីមួយឆ្នាំទៅមួយឆ្នាំ ពិសេស ចាប់ពីដំណាក់កាលនៃការអនុវត្តនយោបាយឈ្នះ ឈ្នះ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ការផ្គត់ផ្គង់ទឹកស្អាតគឺជាអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពទាំងបួននៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៃរាជរដ្ឋាភិបាលអាណត្តិទី៦ ដែលរួមមាន មនុស្ស ផ្លូវ ភ្លើង និងទឹក។ ក្នុងបរិបទនេះ វិស័យផ្គត់ផ្គង់ទឹកស្អាត ទាមទារនូវការពង្រឹងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីធានាការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតដែលមានគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ ដែលអាចបំពេញតម្រូវការប្រើប្រាស់ក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ លើកកម្ពស់សុខុមាលភាពសាធារណៈព្រមទាំងឆ្លើយតបនឹងតម្រូវការផ្នែកមូលដ្ឋានផលិតកម្ម អាជីវកម្ម និងសេវាកម្មលើគ្រប់វិស័យក្នុងសង្គមជាតិទាំងមូល ស្របតាមប្រសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានថ្លែងប្រកាសគាំទ្រជាផ្លូវការចំពោះពាក្យស្លោក *«ទឹកស្អាតសម្រាប់ទាំងអស់គ្នា»* ។

សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត កំណត់អំពីក្របខ័ណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងនិងអភិវឌ្ឍន៍ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងដើម្បីធានាគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ ព្រមទាំងចូលរួមលើកកម្ពស់សុខុមាលភាពសាធារណៈនិងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយបរិយាបន្ន។ ជាមួយគ្នានេះ សេចក្តីព្រាងច្បាប់ខាងលើ ក៏នឹងចូលរួមកសាងទំនុកចិត្តនិងផ្តល់ភាពកក់ក្តៅដល់អ្នកវិនិយោគ រួមទាំងការផ្តល់ហិរញ្ញប្បទានគាំទ្រក្នុងវិស័យទឹកស្អាត ព្រមទាំងផ្តល់សិទ្ធិនិងការការពារតាមផ្លូវច្បាប់ដល់ប្រតិបត្តិករដែលកំពុងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។ តាមរយៈសេចក្តីព្រាងច្បាប់នេះ រាជរដ្ឋាភិបាលនឹងមានសក្តានុពលក្នុងការជំរុញការអនុវត្តគោលនយោបាយលើវិស័យទឹកស្អាត ផែនការយុទ្ធសាស្ត្រដើម្បីស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត លើកកម្ពស់សុខុមាលភាពសាធារណៈ និងរួមចំណែកទ្រទ្រង់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិ។

សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត ត្រូវបានរៀបចំឡើងជា១៥ជំពូក និង៦៥មាត្រា ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

## ៣- សេចក្តីព្រាងគោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ដើម្បីអភិវឌ្ឍ ខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ឆ្នាំ២០២២-២០៣៨

សេចក្តីព្រាងគោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង «គ.ប.ដ.ស.» គឺជាការរៀបចំគោលនយោបាយគ្រប់គ្រងវិស័យដីធ្លី ដែលរួមមានអនុវិស័យរដ្ឋបាលដីធ្លី អនុវិស័យរៀបចំដែនដី អនុវិស័យបែងចែកដីធ្លីនិងលំនៅឋាន ការគ្រប់គ្រងនិងអភិវឌ្ឍវិស័យសំណង់ និងការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាក្នុងខេត្តព្រះសីហនុ ដោយមានការចូលរួមយ៉ាងសកម្មពីវិស័យពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការប្រើប្រាស់ដីធ្លីនិងធនធានធម្មជាតិ និងការធ្វើសមាហរណកម្មវិស័យពាក់ព័ន្ធដីធ្លី ផ្អែកលើមូលដ្ឋាននៃគោលនយោបាយដីធ្លី «សៀវភៅសដីធ្លី» និងគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

សេចក្តីព្រាង គ.ប.ដ.ស. ត្រូវបានរៀបចំឡើងដោយមានចក្ខុវិស័យវែងឆ្ងាយក្នុងការគ្រប់គ្រងនិងប្រើប្រាស់ដី ដើម្បីគាំទ្រដល់ការអភិវឌ្ឍរូបវន្ត សេដ្ឋកិច្ច សង្គមកិច្ច ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ជវភាព សុខភាព និងសុភមង្គលនៅតំបន់ឆ្នេរសមុទ្រកម្ពុជា។ សេចក្តីព្រាង គ.ប.ដ.ស. មានគោលដៅតម្រង់ទិសនិងកំណត់ការគ្រប់គ្រងដីធ្លីនិងប្រើប្រាស់ដីធ្លីខេត្តព្រះសីហនុតាមគន្លងគំរូអភិវឌ្ឍថ្មី ដោយផ្អែកលើកត្តាភូមិសាស្ត្រនៃតំបន់ឆ្នេរសមុទ្រកម្ពុជា កត្តាធនធានធម្មជាតិ បរិស្ថាន វប្បធម៌ និងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ស្របតាមគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ សេចក្តីព្រាងគោលនយោបាយនេះមានវិសាលភាពគ្របដណ្តប់លើដែនដីក្នុងព្រំប្រទល់នៃរដ្ឋបាលខេត្តព្រះសីហនុនិងតំបន់ដែលមានលក្ខណៈអំណោយផលនិងការប្រកួតប្រជែងខ្ពស់ ដោយផ្តល់អាទិភាពខ្ពស់លើតំបន់ឆ្នេរសមុទ្រកម្ពុជា និងតំបន់តាមបណ្តោយផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ ផ្លូវជាតិលេខ៤ ក្នុងរយៈចម្ងាយ ១០០គីឡូម៉ែត្រពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ។

សេចក្តីព្រាង គ.ប.ដ.ស. បានដាក់ចេញនូវចក្ខុវិស័យដល់ឆ្នាំ២០៣៨ «អភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ជាទីក្រុងបៃតងអាស៊ាននៃប៉ូលអភិវឌ្ឍជាតិទំនើបប្រកបដោយចីរភាព ជវភាព សុខភាព និងសុភមង្គល តាមរយៈការជំរុញសមាហរណកម្មការអភិវឌ្ឍទីក្រុងឆ្លាត ការអភិវឌ្ឍបៃតង រមណីយដ្ឋានឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក មជ្ឈមណ្ឌលកំណើនជាតិ មជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិ ច្រកចេញចូលអន្តរជាតិ មជ្ឈមណ្ឌលភស្តុភារកម្មជាតិ ដោយមានទំនាក់ទំនងជាមួយទីផ្សារអាស៊ាននិងសកលលោក និងជាមជ្ឈមណ្ឌលឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យាទំនើប និងនវានុវត្តន៍ ដែលមានសុខដុមនីយកម្មជាមួយនឹងបរិស្ថានរស់នៅល្អប្រសើរ និងរក្សាបាននូវអត្តសញ្ញាណវប្បធម៌និងប្រវត្តិសាស្ត្រជាតិ» និងមានគោលបំណងផ្តល់ក្របខ័ណ្ឌនិងតម្រង់ទិសការគ្រប់គ្រង ការប្រើប្រាស់ដីធ្លី ការបែងចែកដីធ្លី ការអភិវឌ្ឍដែនដីនិងនគរូបនីយកម្ម ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណងប្រកបដោយចីរភាព ជវភាព សុខភាព និងសុភមង្គល ព្រមទាំងមានភាពទាក់ទាញនិងឧត្តមានុវត្តន៍ខ្ពស់ សំដៅរួមចំណែកប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

សេចក្តីព្រាងគោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ឆ្នាំ២០២២-២០៣៨ ត្រូវបានរៀបចំឡើងជា ៧ផ្នែក និងមានឧបសម្ព័ន្ធចំនួន៣ ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

## ៤- សេចក្តីព្រាងគោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧

ដំណាំស្វាយចន្ទី គឺជាដំណាំកសិឧស្សាហកម្មដ៏មានសក្តានុពល និងជាដំណាំអាទិភាពមួយក្នុងចំណោមដំណាំអាទិភាពទាំង១២មុខ ដែលរាជរដ្ឋាភិបាលបាននិងកំពុងផ្តោតការយកចិត្តទុកដាក់លើការបង្កើនផលិតភាពនិងការប្រកួតប្រជែងតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ចក្នុងសកម្មភាពដែលមានតម្លៃខ្ពស់។ បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានខេត្តចំនួន១០ ដែលមានផ្ទៃដីដាំដុះស្វាយចន្ទី ដែលរួមមាន កំពង់ធំ រតនគិរី ក្រចេះ កំពង់ចាម ព្រះវិហារ ស្ទឹងត្រែង ឧត្តរមានជ័យ ត្បូងឃ្មុំ មណ្ឌលគិរី និងសៀមរាប។ ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ ផ្ទៃដីដាំដុះស្វាយចន្ទីកម្ពុជាមានការកើនឡើងពី ៩៤ ៣០៨ហិកតា ដល់ ៤០៥ ៩៩១ហិកតា និងផ្ទៃដីប្រមូលផលបានកើនពី ៧៨ ៥៨៤ហិកតា ដល់ ២៧៥ ៦៧៩ហិកតា ដោយទទួលបានទិន្នផលសរុបកើនពី ៩៣ ៩៥៤តោន ដល់ ៤៧២ ៦៣៦តោន។ ជាមួយគ្នានេះ ស្វាយចន្ទីកម្ពុជាក៏កំពុងមានកេរ្តិ៍ឈ្មោះល្បី និងត្រូវបានទទួលស្គាល់ពីទីផ្សារ លើទំហំគ្រាប់ រសជាតិ កម្រិតកាកសំណល់កសិកម្មទាប និងសរីរាង្គតាមបែបប្រពៃណី ដោយក្នុងនោះផលិតផលស្វាយចន្ទីរបស់កម្ពុជាអាចទាញយកចំណែកទីផ្សារពីសហរដ្ឋអាមេរិក អាល្លឺម៉ង់ ហូឡង់ ចិន ចក្រភពអង់គ្លេស បារាំង អូស្ត្រាលី សហភាពអារ៉ាប់រួម និងជប៉ុន។

ក្នុងន័យនេះ ដើម្បីបន្តជំរុញកំណើនកសិពាណិជ្ជកម្ម ប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាពនិងសុវត្ថិភាព ការដាក់ចេញនូវគោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧ គឺជាការចាំបាច់ ដែលស្របទៅនឹងគោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្ត្រផ្សេងៗទៀត សំដៅធានានូវឧត្តមភាពប្រកួតប្រជែងលើទីផ្សារក្នុងស្រុក តំបន់ និងពិភពលោក ព្រមទាំងជាផែនទីបង្ហាញផ្លូវនិងជាមូលដ្ឋានក្នុងការរៀបចំយុទ្ធសាស្ត្រនិងផែនការសកម្មភាពអភិវឌ្ឍវិស័យដំណាំស្វាយចន្ទីប្រកបដោយចីរភាព។ សេចក្តីព្រាងគោលនយោបាយនេះ មានចក្ខុវិស័យអភិវឌ្ឍផលិតកម្ម ការកែច្នៃ និងទីផ្សារស្វាយចន្ទី ឱ្យមានលក្ខណៈប្រកួតប្រជែងប្រកបដោយបរិយាបន្ន ធានានូវនិរន្តរភាពនិងការធ្វើពិពិធកម្មសេដ្ឋកិច្ច ក្នុងគោលបំណងប្រែក្លាយព្រះរាជាណាចក្រកម្ពុជាឱ្យទៅជាប្រទេសផលិតនិងផ្គត់ផ្គង់ផលិតផលស្វាយចន្ទីដ៏សំខាន់មួយ សម្រាប់បម្រើដល់ទីផ្សារក្នុងស្រុក តំបន់ និងពិភពលោក។

សេចក្តីព្រាងគោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧ ត្រូវបានរៀបចំឡើងជា ៧ផ្នែក និងមានឧបសម្ព័ន្ធចំនួន២ ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

## ៥- បញ្ហាផ្សេងៗ

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា៖

- រាជរដ្ឋាភិបាលសម្រេចផ្តល់ដីនិងផ្ទះដែលជាទ្រព្យសម្បត្តិរដ្ឋ ដែលលោក គង់ គាំ បានស្ម័គ្រចិត្តប្រគល់ត្រឡប់ជូនក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិវិញ ទៅឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីប្រើប្រាស់ធ្វើជាទីស្នាក់ការរបស់ គ.ជ.ប.

- រាជរដ្ឋាភិបាលលើកទឹកចិត្តឱ្យក្រសួងស្ថាប័នពាក់ព័ន្ធនិងវិស័យឯកជន ជំរុញការអភិវឌ្ឍផលិតកម្មនិងការកែច្នៃផលិតផលកសិកម្មឬកសិឧស្សាហកម្ម មានជាអាទិ៍ ស្រូវ កៅស៊ូ ដំឡូងមី និងស្វាយចន្ទី ជាដើម ដើម្បីបង្កើនតម្លៃបន្ថែម និងពង្រីកទីផ្សារនៃការនាំចេញ

- រាជរដ្ឋាភិបាលជំរុញក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការនិងដឹកជញ្ជូន ឱ្យពន្លឿនការសិក្សាគម្រោងសាងសង់ផ្លូវរថភ្លើងល្បឿនលឿន ពីរាជធានីភ្នំពេញទៅខេត្តព្រះសីហនុ និងផ្លូវរថភ្លើងល្បឿនលឿនពីរាជធានីភ្នំពេញទៅក្រុងប៉ោយប៉ែត ដោយអភិវឌ្ឍលើផ្លូវរថភ្លើងដែលមានស្រាប់ ដើម្បីបម្រើឱ្យវិស័យដឹកជញ្ជូនកាន់តែសម្បូរបែប ជំរុញកំណើនសេដ្ឋកិច្ច-សង្គមកម្ពុជា ឱ្យកាន់តែរីកចម្រើន បង្កើនប្រាក់ចំណូល និងលើកកម្ពស់ជីវភាពប្រជាជន។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១២និង១៥នាទី។

ថ្ងៃសុក្រ ៧រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣